**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១០០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពល-ខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ .-**

អនុលោមតាមមាត្រា២ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ក្រុមប្រឹក្សាយោធាត្រូវបានបង្កើតឡើងនៅក្រសួងការពារជាតិ ដើម្បីពិនិត្យបទដ្ឋានច្បាប់ទាំងឡាយដែលទាក់ទងទៅនឹងបញ្ហាយោធា ដែលមានសមាសភាព៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងការពារជាតិ | ប្រធាន |
| - អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងការពារជាតិគ្រប់រូប | សមាជិក |
| - អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទគ្រប់រូប | សមាជិក |
| - អគ្គលេខាធិការក្រសួងការពារជាតិ | សមាជិក |
| - សាកលវិទ្យាធិការ សាកលវិទ្យាល័យការពារជាតិ | សមាជិក |
| - នាយក នាយកដ្ឋានបុគ្គលិក | សមាជិក |
| - នាយក នាយកដ្ឋាននីតិកម្ម | លេខាធិការ |

**មាត្រា២ .-**

ក្រុមប្រឹក្សាយោធាមានភារកិច្ចពិនិត្យ សិក្សា ពិចារណា ដើម្បីរៀបចំសម្រួលរាល់លិខិតបទដ្ឋានទាំងឡាយដែលទាក់ទងនឹងយោធាមុននឹងផ្ញើជូនទៅគណៈរដ្ឋមន្ត្រីសម្រេច។

ក្រុមប្រឹក្សាយោធាធ្វើការប្រជុំពេញអង្គដើម្បីធ្វើសេចក្តីសម្រេច ប្រព្រឹត្តទៅក្រោមអធិបតីភាពនៃរដ្ឋមន្ត្រីក្រសួងការពារជាតិ និងអាចអញ្ជើញបន្ថែមសមាសភាពដែលមានការពាក់ព័ន្ធចូលរួម។

សមាជិកក្រុមប្រឹក្សាយោធាត្រូវចូលរួមប្រជុំតាមការកំណត់របស់ប្រធាន ករណីអវត្តមានត្រូវមានការអនុញ្ញាតពីប្រធាន។

កិច្ចប្រជុំពេញអង្គក្រុមប្រឹក្សាយោធារៀបចំឡើងដោយអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ។

**មាត្រា៣ .-**

ត្រូវបានបង្កើតក្រុមការងារស្រាវជ្រាវមួយសម្រាប់ជួយការងារក្រុមប្រឹក្សាយោធា ដែលមានសមាសភាព៖

| | |
|---|---|
| - រដ្ឋលេខាធិការ ក្រសួងការពារជាតិ ០១រូប | ប្រធាន |
| - អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ មួយចំនួន | សមាជិក |
| - មេបញ្ជាការ ឬមេបញ្ជាការរង កងទ័ពជើងគោក ០១រូប | សមាជិក |
| - មេបញ្ជាការ ឬមេបញ្ជាការរង កងទ័ពជើងទឹក ០១រូប | សមាជិក |
| - មេបញ្ជាការ ឬមេបញ្ជាការរង កងទ័ពជើងអាកាស ០១រូប | សមាជិក |
| - មេបញ្ជាការ ឬមេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស ០១រូប | សមាជិក |
| - អគ្គលេខាធិការរង ក្រសួងការពារជាតិ ០១រូប | សមាជិក |
| - អគ្គនាយក ឬអគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស ០១រូប | សមាជិក |
| - អគ្គនាយក ឬអគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ ០១រូប | សមាជិក |
| - អគ្គនាយក ឬអគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា ០១រូប | សមាជិក |

- សាកលវិទ្យាធិការរង សាកលវិទ្យាល័យការពារជាតិ ០១រូប សមាជិក
- អគ្គនាយក ឬអគ្គនាយករង អគ្គនាយកដ្ឋាននយោបាយនិងកិច្ចការបរទេស ០១រូប សមាជិក
- អគ្គនាយក ឬអគ្គនាយករង មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម ០១រូប សមាជិក
- អគ្គនាយក ឬអគ្គនាយករង អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច ០១រូប សមាជិក
- នាយក ឬនាយករង ខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាន ០១រូប សមាជិក
- មេបញ្ជាការ ឬមេបញ្ជាការរង គ្រប់យោធភូមិភាគ ០១រូប សមាជិក
- ប្រធាន ឬអនុប្រធាន ស្ថាប័នអយ្យការយោធា ០១រូប សមាជិក
- ប្រធាន ឬអនុប្រធាន ស្ថាប័នតុលាការយោធា ០១រូប សមាជិក
- នាយក ឬនាយករង នាយកដ្ឋានអធិការកិច្ច ០១រូប សមាជិក
- នាយករង នាយកដ្ឋានបុគ្គលិក ០១រូប សមាជិក
- នាយក ឬនាយករង ទីចាត់ការបុគ្គលិក ០១រូប សមាជិក
- នាយក ឬនាយករង ទីចាត់ការហិរញ្ញវត្ថុ ០១រូប សមាជិក
- នាយក ឬនាយករង នាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច ០១រូប សមាជិក
- នាយក ឬនាយករង អធិការដ្ឋានរគ្គបញ្ជាការដ្ឋាន ០១រូប សមាជិក
- នាយក នាយកដ្ឋាននីតិកម្ម លេខាធិការ

**មាត្រា៤ .-**

ក្រុមការងារស្រាវជ្រាវមានភារកិច្ចដូចតទៅ៖

-សិក្សាស្រាវជ្រាវអំពីការតាក់តែង ការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋាននានាដូចជា ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីសម្រេចទាំងឡាយដែលទាក់ទងនឹងកងយោធពលខេមរភូមិន្ទឱ្យបានត្រឹមត្រូវតាមទម្រង់បែបបទ និងស្របតាមឋានានុក្រមលិខិតបទដ្ឋានដែលនៅជាធរមាន មុននឹងដាក់ជូនប្រជុំពេញអង្គក្រុមប្រឹក្សាយោធា ឬដាក់ជូនប្រធានក្រុមប្រឹក្សាយោធាពិនិត្យសម្រេច

-ទំនាក់ទំនងសហការជាមួយស្ថាប័ន អង្គភាពក្នុងកងយោធពលខេមរភូមិន្ទ និងស្ថាប័នអង្គភាពស៊ីវិលផ្សេងៗទៀត ដើម្បីពិនិត្យកែសម្រួលខ្លឹមសារលិខិតបទដ្ឋានទាំងឡាយឱ្យបានស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងកងយោធពលខេមរភូមិន្ទ

-ធ្វើកិច្ចការមួយចំនួនទៀតតាមការប្រគល់ភារកិច្ចបន្ថែមពីប្រធានក្រុមប្រឹក្សាយោធា

-ក្រុមការងារស្រាវជ្រាវបន្ទាប់ពីបានធ្វើការប្រជុំ ត្រូវធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលជូនប្រធានក្រុមប្រឹក្សាយោធាធ្វើការពិនិត្យសម្រេច

-សមាជិកក្រុមការងារស្រាវជ្រាវត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ករណីអវត្តមានត្រូវសុំការអនុញ្ញាតពីប្រធាន។

**មាត្រា៥ .-**

ការតែងតាំងសមាសភាពនៃក្រុមប្រឹក្សាយោធា និងក្រុមការងារស្រាវជ្រាវដូចមានចែងក្នុងមាត្រា១ និងមាត្រា៣ នៃអនុក្រឹត្យនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា៦ .-**

អនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធា និងអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា៣ នៃអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៣ រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ បាញ់**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៧
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ